ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងរដ្ឋប្បវេណី

លេខ:១០/១៦-១២-២០១៣

ដីកាសម្រេច

លេខ: ០២ក្រ IV ត "ដ.ក.ស"

ចុះថ្ងៃទី ១០-០១-២០១៤

## ដីកាសម្រេច

ក្រុមប្រឹក្សាទី ៤ នៃសំណុំរដ្ឋប្បវេណីសាលាឧទ្ធរណ៍ ដែលមានសមាសភាព :

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

ក្រឡាបញ្ជី

លោកស្រី [redacted]

-ដើមចោទឈ្មោះ [redacted] ស៊ុនណាឆុង អាយុ៥០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៦១ ផ្លូវ៥៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

មេធាវី-អ្នកតំណាងដោយអាណត្តិ លោក [redacted]

-ចុងចម្លើយឈ្មោះ [redacted] គីមហៀង អាយុ៥០ឆ្នាំ ជាតិខ្មែរ ។

មេធាវី-អ្នកតំណាងដោយអាណត្តិ [redacted]

-ខ្លឹមសារនៃការទាមទារៈប្ដឹងសុំជំនុំជំរះសារជាថ្មីលើដីកាសម្រេចលេខ១១ក្រ៣ "ច" ដកស ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ។

**ការអះអាងរបស់ដើមចោទៈឈ្មោះ** [redacted] ស៊ុនណាឆុង បញ្ជាក់ថា កិច្ចព្រមព្រៀងខ្លួនអនុវត្តរហូតមកពុំមានគេចវេសម្ដងណាទេ តែភាគី [redacted] គីមហៀង មិនអនុវត្តដោយរាំងស្ទះមិនឱ្យខ្លួនលក់សណ្ឋាគារនោះបាន ហើយហាមឃាត់ខ្លួនកាត់ឈ្មោះផ្ទេរកម្មសិទ្ធិ ។

លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ស៊ុនណាឆុង បញ្ជាក់ថា ខ្លួនសុំជំនុំជំរះសារជាថ្មី ដោយសារសារសាលាឧទ្ធរណ៍ចេញដីកាសំរេចធ្វើឱ្យខូចប្រយោជន៍កូនក្តីខ្លួន ព្រោះការវាយតម្លៃតែលើដី និងអគារមិនបញ្ចូលនូវអចលនទ្រព្យផ្សេងៗទៀត មានគ្រឿងសង្ហារឹម ព្រមទាំងសំភារៈបំពាក់ក្នុងសណ្ឋាគារដែលមានតម្លៃរាប់លានដុល្លាអាមេរិកនៅក្នុងការដេញថ្លៃ ហើយនៅសាលាដំបូងវាយតម្លៃដំបូង៤លានដុល្លា ដល់ក្រោយមកបានតែ៣លានដុល្លា ។ នីតិវិធីអនុវត្តបានបំពារលើកិច្ចព្រមព្រៀង ព្រោះថា ទុកពេលឱ្យកូនក្តីខ្លួនលក់រយៈពេល២ឆ្នាំ តែបានជាង





Scanned with CamScanner

មួយឆ្នាំក៏មានរក្សាការពារផ្អាកកូនក្ដីខ្លួនវិញ។. ពាក្យសុំបញ្ចូលភស្ដុតាង គឺឯកសារនេះ ខ្លួនទើបតែដាក់មកទេ ពុំរ៉ែលើកឡើងក្នុងនីតិវិធីពេលមុនឡើយ ។

សំណូមពរៈសុំផ្អាកអនុវត្តដីកាសម្រេចលេខ១១ក្រពា ៉ ច ៉ ដកស ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ .សុំបដិសេធដីកាសម្រេចនេះ និងសុំធ្វើការវាយតម្លៃជាថ្មីលើសណ្ឋាគារ ។

លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ស៊ុនណាផុង បញ្ជាក់ថា ចំណុចបញ្ជាក់ជូនមានក្នុងពាក្យបណ្ដឹងសុំ ហើយជាចំណុចថ្មីខ្លួនទើបរកឃើញ គឺការវាយតម្លៃពុំបានធ្វើលើអចលនទ្រព្យទើបធ្វើឱ្យតម្លៃធ្លាក់ចុះ ។

**ការអះអាងរបស់ចុងចម្លើយៈ** លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] គឹមហៀង បញ្ជាក់ថា ការសុំជំនុំជំរះសាជាថ្មី លើដីកាសម្រេចលេខ១១ក្រពា ៉ ច ៉ ដកស ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ បើតាមសេចក្ដីថ្លែងការណ៍របស់ភាគីបណ្ដឹងគឺពុំមានបង្ហាញភស្ដុតាងថ្មីទេ សុទ្ធតែបានលើកឡើងបង្ហាញពេលជំនុំជំរះមុនៗរួចហើយ ។ ការដេញថ្លៃធ្វើឡើងដល់៤ដង រឿងនេះជាសំណុំរឿងអនុវត្ត មានដីកាសម្រេចឱ្យលក់ ។ នៅសាលាដំបូងកំណត់តម្លៃលក់អប្បបរមា ភាគីដើមចោទពុំបានប្ដឹងជំទាស់ទេ ហើយការតវ៉ារបស់គាត់ពេលនេះគឺដដែលៗ ។ ខ្លួនសុំក្រុមប្រឹក្សាសំរេចច្រានចោលពាក្យសុំតាមមាត្រា ៣១៤ ចំណុចទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ។

លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យអ្នកដេញថ្លៃបាន បញ្ជាក់ថា ក្នុងសំណុំរឿងអនុវត្ត មេធាវីដើមបណ្ដឹងសុំជំនុំជំរះសារជាថ្មីធ្លាប់លើកមូលហេតុនេះពេលមុនរួចហើយ ពុំមែនថ្មីទេ ។ កូនក្ដីខ្លួនដេញថ្លៃបាន ត្រូវបានតុលាការបង្គាប់ឱ្យដាក់ប្រាក់កក់ជាង៣០ម៉ឺនដុល្លា សំណូមពរសុំច្រានចោលបណ្ដឹងសុំជំនុំជំរះសារជាថ្មី ។

## សំអាងហេតុ

១-បណ្ដឹងសុំឱ្យជំនុំជម្រះសារជាថ្មីចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] ស៊ុនណាផុង លើដីកាសម្រេចលេខ១១ក្រពា ៉ ច ៉ ដកស ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ធ្វើឡើងត្រឹមត្រូវតាមទម្រង់យោងតាមមាត្រា៣១២នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២-មូលហេតុដែលលើកឡើងដោយដើមចោទ ជាអាទិ៍ ការអះអាងពីការបំពានកិច្ចព្រមព្រៀង និងកំណត់ហេតុសះជា. ការវាយតម្លៃអប្បបរមាលើសណ្ឋាគារមានលក្ខណៈមិនប្រក្រតី និងមិនបានពិចារណាលើតម្លៃគ្រឿងសង្ហារិមព្រមទាំងសំភារៈបំពាក់ក្នុងសណ្ឋាគារ. ការផ្លាស់ប្ដូរតម្លៃអប្បបរមាច្រើនលើកច្រើនសារដោយតុលាការ. នីតិវិធីនៃការដេញថ្លៃធ្វើឡើងដោយមិនត្រឹមត្រូវ ត្រូវបានដើមចោទលើកឡើងរួចហើយនៅក្នុងនីតិវិធីចេញដីកាសម្រេចលេខ១១ក្រពា ៉ ច ៉ ដកស ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដូចមានសរសេរក្នុងផ្នែកសំអាងហេតុនៃដីកាសម្រេចឃើញថា ដើមចោទពុំបានលើកយកមូលហេតុថ្មីដូចបានកំណត់ក្នុងមាត្រា៣០៧នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលអាចឱ្យតុលាការពិចារណាលើការប្ដឹងសុំបានឡើយ ។

៣-ភាគីចុងចម្លើយបានអះអាងថា មូលហេតុទាំងឡាយដែលបានលើកឡើងត្រូវបានប្រើប្រាស់រួចហើយនៅក្នុងនីតិវិធីសាលាដំបូងក៏ដូចជានៅសាលាឧទ្ធរណ៍ ពុំមានមូលហេតុអាចឱ្យធ្វើការជំនុំជម្រះសាជាថ្មីបានទេសុំច្រានចោលពាក្យសុំ ។

៤-ការអះអាងរបស់ដើមចោទ គ្មានមូលហេតុត្រឹមត្រូវដើម្បីធ្វើការជំនុំជម្រះសាជាថ្មីដែលបានកំណត់ក្នុងមាត្រា ៣០៧ទេ គប្បីច្រានចោលបណ្តឹងតាមមាត្រា៣១៤ កថាខណ្ឌទី២នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ហេតុដូច្នេះសម្រេច

១-ច្រានចោលបណ្តឹងសុំជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] ស៊ុនណាឆុង ប្តឹងសុំជំនុំជម្រះសាជាថ្មីលើដីកាសម្រេចលេខ១១ក្រ៣ ច ដកស ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុក របស់ឈ្មោះ [redacted] ស៊ុនណាឆុង ។

ដីកាសម្រេចនេះប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤។

ក្រឡាបញ្ជី　　　　ចៅក្រមប្រឹក្សា　　　　ប្រធានក្រុមប្រឹក្សា

ហត្ថលេខា : [redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី...... ខែ.មករា...ឆ្នាំ ២០១៤
ក្រឡាបញ្ជី

[redacted]



៤៨៧

487